**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

# សារថ្វាយព្រះពរ

## សូមក្រាបបង្គំទូលថ្វាយ

## សម្ដេចព្រះមហាក្សត្រី នរោត្ដម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាពសេចក្ដីថ្លៃថ្នូរ និងសុភមង្គល ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់

ក្នុងឱកាសដ៏នក្ខត្តឫក្ស នៃទិវាចូលឆ្នាំថ្មីឆ្នាំសកល គ្រិស្តសករាជ២០១៧ ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា ក្នុងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ នៃកងយោធពលខេមរភូមិន្ទ ក្នុងនាមភរិយាខ្ញុំ និងខ្លួនខ្ញុំផ្ទាល់ សូមលំឱនកាយវាចាចិត្តក្រាបបង្គំទូលថ្វាយនូវព្រះសព្ទសាធុការពរជ័យ បវរសួស្តី សិរីវឌ្ឍនា វិបុលសុខ មហាប្រសើរគ្រប់យ៉ាង សូម**សម្ដេចព្រះមហាក្សត្រី** ទ្រង់ប្រកបដោយព្រះរាជសុខភាពល្អបរិបូរណ៍ ព្រះកាយពលរឹងមាំ ព្រះជន្មយឺនយូរ ចាកផុតពីព្រះរោគាព្យាធិនានា ដើម្បីភាពសុខដុមរមនា សម្បូរសប្បាយចម្រុងចម្រើនថ្កុំថ្កើងរុងរឿង និងជាទីសង្ឃឹមដល់ប្រជានុរាស្ត្រគ្រប់ៗរូប ទាំងក្នុងបច្ចុប្បន្ននិងទៅអនាគត។

ឆ្លៀតក្នុងឱកាសដ៏មហាជ័យមង្គលប្រសើរថ្លៃថ្លានេះ ទូលព្រះបង្គំ **ជាកូន ចៅ ចៅទួត** ទាំងអស់គ្នា សូមព្រះបរមរាជានុញ្ញាតសម្តែងថ្វាយនូវអំណរសាទរឥតឧបមា ប្រកបដោយកត្តញ្ញូកតវេទិតាធម៌ដ៏ខ្ពង់ខ្ពស់បំផុតចំពោះព្រះរាជហឫទ័យ និងព្រះរាជសកម្មភាពប្រកបដោយព្រះគុណធម៌ របស់**សម្ដេចព្រះមហាក្សត្រី** ក្នុងវិស័យសង្គមកិច្ច អប់រំសិក្សាធិការ ពិសេសលើវិស័យមនុស្សធម៌ ជួយដល់ប្រជានុរាស្ត្រទីទ័លក្រលំបាក និងប្រជានុរាស្ត្រ រងគ្រោះដោយសារគ្រោះធម្មជាតិផ្សេងៗ។

ជាថ្មីម្តងទៀត ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា សូមលំឱនកាយវាចាចិត្តបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ ព្រមទាំងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក មានទេវតារក្សាព្រះមហាស្វេតច្ឆត្រ ព្រមទាំងព្រះរាជតេជបារមី នៃព្រះអតីត ព្រះមហាក្សត្រ ព្រះមហាក្សត្រីយានីខ្មែរគ្រប់ព្រះអង្គ ជាពិសេសព្រះបរមសពព្រះបរមរតនកោដ្ឋ សូមទ្រង់ព្រះមេត្តាប្រោសព្រះរាជទាននូវព្រះរាជស័ព្ទសាធុការពរជ័យ ថ្វាយចំពោះ **សម្ដេចព្រះមហាក្សត្រី** ជាទីគោរពសក្ការៈ សូមព្រះអង្គទ្រង់ប្រកបដោយព្រះរាជសុខភាពល្អបរិបូរណ៍ ព្រះជន្មាយុយឺនយូរ ដើម្បីព្រះអង្គទ្រង់គង់ប្រថាប់នៅជាម្លប់ដ៏ត្រជាក់ត្រែមក្សាន្តដល់ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា និងប្រជានុរាស្ត្រ**ជាកូន ជាចៅ ចៅទួត** របស់ព្រះអង្គអស់កាលជានិច្ចនិរន្តរ៍តរៀងទៅ។

សូម **សម្ដេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្ដីថ្លៃថ្នូរ និងសុភមង្គល** ជាទីគោរពសក្ការៈ ទ្រង់ព្រះមេត្តាទទួលនូវគារវភក្តីភាពដ៏ខ្ពង់ខ្ពស់បំផុតអំពីទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា។

សេចក្ដីគួរពុំគួរ សូមទ្រង់ព្រះមេត្តាប្រោស ។

សូមក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី១៥ ខែ ធ្នូ ឆ្នាំ ២០១៦

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ ប៉ាញ់**